**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ១៤២៩ សហវ.ប្រក

# ប្រកាសអន្តរក្រសួង

## ស្តីពី

## ការបង្កើតវិធានបុរេប្រទានសម្រាប់ឆ្នាំ ២០១៦ របស់ អាជ្ញាធរទន្លេសាប ( ក្រសួងធនធានទឹក និងឧតុនិយម )

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម និងជា ប្រធានអាជ្ញាធរទន្លេសាប**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៩១៣/៩០៣ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និង បំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/ន.ស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការ រៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខនស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តី ពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសអោយប្រើ ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៥/០១៦ ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៥ ដែលប្រកាសអោយប្រើច្បាប់ស្តីពី ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៦
- បានឃើញអនុក្រឹត្យលេខ ៨៨ អនក្រ.បក ចុះថ្ងៃទី ១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១១៦ អនក្រ.បក ចុះថ្ងៃទី៣០ ខែកក្កដា ឆ្នាំ ២០០៩ ស្តីពីការរៀបចំ និងការព្រឹត្តទៅរបស់ អាជ្ញាធរទន្លេសាប
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៨១ អនក្រ.បកចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុលើ ការចំណាយថវិការដ្ឋនៅតាម ក្រសួង ខេត្ត ក្រុង ក្រុងស្វយ័ត រាជធានីភ្នំពេញ និងអង្គការសាធារណៈរដ្ឋបាល
- បានឃើញប្រកាសលេខ ០០៤ សហវ.ម.ប្រក ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការអនុវត្តបទបញ្ជាទូទៅ នៃ គណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ ១៨៩ សហវ.ប្រក ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៣ ស្តីពីការដាក់អោយអនុវត្តន៍ចំណាត់ថ្នាក់ សេដ្ឋកិច្ច នៃមាតិកាថវិកា របស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញប្រកាសលេខ ២១១ សហវ.ប្រក ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៣ ស្តីពីការដាក់អោយអនុវត្តន៍មាតិកា គណនីនៃប្លង់គណនេយ្យថវិការបស់រដ្ឋបាលថ្នាក់ជាតិ រដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញប្រកាសលេខ ១៩៣៧ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីនីតិវិធីចំណាយតាមវិធានបុរេ ប្រទាន សម្រាប់រដ្ឋបាលថ្នាក់ជាតិ

- ប្រកាសលេខ ៨២៩ សហវ.ប្រក ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ ២០១៥ ស្តីពីការកែសម្រួលប្រការ ៤ ប្រការ ៥ ប្រការ ១៤ និងប្រការ ១៧ នៃប្រកាសលេខ ១៩៣៧ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ ២០១៤ ស្តីពីនីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទាន សម្រាប់រដ្ឋបាលថ្នាក់ជាតិ
- យោងតាមតម្រូវការចាំបាច់ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបច្ចុប្បន្ន
- យោងតាមតម្រូវការចាំបាច់របស់ អាជ្ញាធរទន្លេសាប (ក្រសួងធនធានទឹក និងឧតុនិយម)

## សម្រេច

**ប្រការ ១:**

ត្រូវបានបង្កើតរជ្ជទេយ្យបុរេប្រទាន ជំពូក ៦៥ នៅ អាជ្ញាធរទន្លេសាប (ក្រសួងធនធានទឹក និងឧតុនិយម) សម្រាប់មុខសញ្ញាចំណាយដូចមានចែងក្នុងប្រការ ៥ ថ្មី នៃប្រកាសលេខ ៨២៩ សហវ.ប្រក ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ ២០១៥ ស្តីពីការកែសម្រួលប្រការ ៤ ប្រការ ៥ ប្រការ ១៤ និងប្រការ ១៧ នៃប្រកាសលេខ ១៩៣៧ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ ២០១៤ ស្តីពីនីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទាន សម្រាប់រដ្ឋបាលថ្នាក់ជាតិ ។

តារាងឧបសម្ព័ន្ធរជ្ជទេយ្យបុរេប្រទាន ត្រូវបានកំណត់ជាឧបសម្ព័ន្ធនៃប្រកាសនេះ ។

**ប្រការ ២:**

ចំនួនទឹកប្រាក់មួយជុំបង្វិល នៃរជ្ជទេយ្យបុរេប្រទាន ត្រូវកំណត់ក្នុងតារាងឧបសម្ព័ន្ធរជ្ជទេយ្យបុរេប្រទាន ។

**ប្រការ ៣:**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសអន្តរក្រសួងនេះត្រូវទុកជានិរាករណ៍ ។

**ប្រការ ៤:**

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានរតនាគារជាតិ អគ្គនាយកនៃអគ្គនាយកដ្ឋានថវិកា អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន ប្រធាននាយកដ្ឋាន ប្រធានអង្គភាពទទួលបន្ទុករដ្ឋបាល និងហិរញ្ញវត្ថុ របស់ អាជ្ញាធរទន្លេសាប ប្រធានគ្រប់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងអាជ្ញាធរទន្លេសាប ត្រូវទទួលបន្ទុកអនុវត្តន៍ប្រកាសអន្តរក្រសួងនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែ មីនា ឆ្នាំ ២០១៦

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន**

**រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម**
**និងជា ប្រធានអាជ្ញាធរទន្លេសាប**

**លឹម គានហោ**

**កន្លែងទទួល៖**
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងមុខងារសាធារណៈ
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
-សាលារាជធានី ខេត្ត
-ដូចប្រការ៤
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងធនធានទឹក និងឧតុនិយម
អាជ្ញាធរទន្លេសាប

## តារាងឧបសម្ព័ន្ធរដ្ឋទេយ្យបុរេប្រទានថវិកាកម្មវិធីឆ្នាំ ២០១៦ របស់ អាជ្ញាធរទន្លេសាប

| ជំពូក | គណនី | អនុគណនី | បរិយាយ | ច្បាប់ហិរញ្ញវត្ថុឆ្នាំ២០១៦ | ឥណទានដែលជ្រើសរើស | ឥណទានរដ្ឋទេយ្យឆ្នាំ២០១៦ | ឥណទានទូទាត់ធម្មតា | ឥណទានខ្ទង់បង្វិលរដ្ឋទេយ្យបុរេប្រទាន | ភាគរយ |
|---|---|---|---|---|---|---|---|---|---|
| 65 | | | ឧបត្ថម្ភធន | 7,746,000,000៛ | | | | | |
| | 6502 | | ឧបត្ថម្ភដល់អង្គការសាធារណៈ | 5,500,000,000៛ | | | | | |
| | | 65026 | ឧបត្ថម្ភធនដល់អង្គភាពដែលមានលក្ខណៈរដ្ឋបាល | 5,500,000,000៛ | 4,000,000,000៛ | 1,200,000,000៛ | 2,800,000,000៛ | 300,000,000៛ ✓ | 30% |
| | | សរុប | | | | 1,200,000,000៛ | 2,800,000,000៛ | 300,000,000៛ | |

បានឃើញ និងពិនិត្យត្រឹមត្រូវ
ថ្ងៃទី ខែ ឆ្នាំ ២០១៦
ជ. អគ្គនាយក
អគ្គនាយកដ្ឋានរតនាគារជាតិ

បានឃើញ និងពិនិត្យត្រឹមត្រូវ
ថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០១៦
ជ. អគ្គនាយក
អគ្គនាយកដ្ឋានថវិកា

អ៊ុក សុវណ្ណារ៉ា

បានឃើញ និងពិនិត្យត្រឹមត្រូវ
ថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០១៦
អគ្គលេខាធិការ
អគ្គលេខាធិការដ្ឋានអាជ្ញាធរទន្លេសាប

ហ៊ែល-ត្នូនី

ថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០១៦
រដ្ឋទេយ្យករបុរេប្រទាន

សរ-គឹមសាន្ត

បានឃើញ និងឯកភាព
ថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០១៦
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន

បានឃើញ និងឯកភាព
ថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០១៦
រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម
និងជា ប្រធានអាជ្ញាធរទន្លេសាប

លឹម គានហោ